- បានឃើញ ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញ អនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៣៨អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពីគ្រប់គ្រង និងការត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និង ការប្រើប្រាស់អាវុធជាតិផ្ទុះ គ្រប់ប្រភេទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅកំណត់ពីលក្ខខណ្ឌ និង នីតិវិធីក្នុងការគ្រប់គ្រងកាំភ្លើង គ្រាប់បាញ់

និងគ្រឿងផ្ទុះ ដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលប្រកាសដោយព្រះរាជក្រម លេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៥ ។

មាត្រា ២.-

អនុក្រឹត្យនេះមានគោលបំណងការពារសន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ។

មាត្រា ៣.-

វិសាលភាពនៃអនុក្រឹត្យនេះគ្របដណ្តប់លើ ការកាន់កាប់ ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការឱ្យខ្ចី ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់ ។

មាត្រា ៤.-

វាក្យសព្ទ ដូចចែងក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម ÷

ក. កាំភ្លើងកំណត់សញ្ញា : សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណងដើម្បីបាញ់ចេញបន្លឺសំឡេង ឬ ចេញភ្លើង ផ្សែង សម្រាប់កំណត់សញ្ញា ឬ ទីកន្លែង ។

ខ. កាំភ្លើងកីឡា : សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណង ដើម្បីហាត់ហ្វឹកហ្វឺន ឬ ប្រកួតក្នុងសកម្មភាពកីឡា ។

គ. កាំភ្លើងសិល្បៈ : សំដៅដល់កាំភ្លើងដែលផលិតឡើងក្នុងគោលបំណងប្រើប្រាស់សម្រាប់ការសំដែងសិល្បៈ អាចបាញ់ចេញបន្លឺសម្លេង ឬ អណ្តាតភ្លើងតែគ្មានក្បាលគ្រាប់ ។

ឃ. បំពង់ និងគ្រាប់កាំជ្រួចផ្ទុះលម្អ : សំដៅដល់ ឧបករណ៍ដែលគេផលិតឡើង ក្នុងគោលបំណងដើម្បីបាញ់បញ្ជូនគ្រាប់កាំជ្រួចទៅលើអាកាស ផ្ទុះបន្លឺសម្លេង និង/ឬ បែកចេញផ្កាភ្លើង គ្មានបំណែកអម្បែងលោហៈ ។

ង. គ្រាប់បាញ់ : សំដៅដល់ គ្រាប់ ឬកិបសម្រាប់បាញ់ជាមួយកាំភ្លើងដូចបានចែងក្នុងកថាខណ្ឌ ក.ខ.គ និង ឃ ។

ច. គ្រឿងផ្ទុះ : សំដៅដល់ កិបផ្ទុះ ខ្សែឆ្នួនផ្ទុះ ខ្សែឆ្នួនឆេះ រំសេវ ជាតិផ្ទុះ និង សារធាតុផ្ទុះគ្រប់ប្រភេទ ទោះជាមានដើមកំណើតពីអ្វីក៏ដោយសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ឬ ផ្ទុះលម្អ ។

ជំពូកទី ២
លក្ខខណ្ឌ និង នីតិវិធី
ក្នុងការគ្រប់គ្រង និងការអនុញ្ញាតឱ្យប្រើប្រាស់

មាត្រា ៥.-

កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវចុះបញ្ជីគ្រប់គ្រងតាមគំរូឯកភាពកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៦.-

លក្ខខណ្ឌក្នុងការអនុញ្ញាតឱ្យប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដូចខាងក្រោម ÷

- អ្នកស្នើសុំត្រូវតែជារូបវន្តបុគ្គល ដែលមានសញ្ជាតិខ្មែរ មានអាយុ ១៨ ឆ្នាំឡើង និងមាននីតិសម្បទាគ្រប់គ្រាន់ ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ។
- គោលបំណង និងសំណូមពរ នៃការស្នើសុំ ត្រូវស្របនឹងភាពចាំបាច់ក្នុងមុខរបរ អាជីព ឬ វិជ្ជាជីវៈ ។
- កាំភ្លើង គ្រាប់បាញ់ ឬ គ្រឿងផ្ទុះ ត្រូវបានផលិតឡើងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស មានប្រវត្តិ និងអត្តសញ្ញាណច្បាស់លាស់ ។
- មានការធានាទទួលខុសត្រូវលើផលវិបាកផ្សេងៗ ដែលកើតមានឡើង ។
- គោរពការណែនាំរបស់ក្រសួងមានសមត្ថកិច្ច ពីវិធាននានា ក្នុងការគ្រប់គ្រង ឬកិច្ចការពារសុវត្ថិភាព និរភ័យក្នុងការដឹកជញ្ជូន ការស្តុក និងការបញ្ចេញប្រើប្រាស់ ។
- បំពេញកាតព្វកិច្ចផ្សេងទៀតដែលច្បាប់បានកំណត់ ។

មាត្រា ៧.-

នីតិវិធីក្នុងការស្នើសុំលិខិតអនុញ្ញាត ឬ ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៨.-

បរិមាណ ប្រភេទ គុណភាពកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ ស្របតាមលក្ខខណ្ឌ ដូចបានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យសម្រេចដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៩.-

កាំភ្លើង គ្រាប់បាញ់ ឬគ្រឿងផ្ទុះ និងលិខិតអនុញ្ញាតទាំងឡាយ ឬប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់ត្រូវតែបានបង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅពេលមានសំណូមពរត្រួតពិនិត្យ ។

ជំពូកទី ៣
សមត្ថកិច្ចគ្រប់គ្រង

មាត្រា ១០.-

ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១១.-

ការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងគ្រឿងផ្ទុះ សម្រាប់បម្រើសេវាកម្មសាធារណៈ និង វិស្វកម្មស៊ីវិល ដូចបានចែងក្នុងកថាខណ្ឌ ច មាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវដោយក្រសួងមហាផ្ទៃ ។

មាត្រា ១២.-

ការដឹកជញ្ជូនគ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និង វិស្វកម្មស៊ីវិលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មធ្យោបាយដឹកជញ្ជូន និង ការពារសុវត្ថិភាព និរភ័យ ត្រូវរ៉ាប់រងដោយកងកម្លាំងនគរបាលជាតិ ។

មាត្រា ១៣.-

ឃ្លាំងស្តុកគ្រឿងផ្ទុះត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌបច្ចេកទេសអំពីប្រព័ន្ធការពារសុវត្ថិភាព និរភ័យ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា ១៤.-

ស្ថាប័នសាធារណៈ អង្គការប្រតិបត្តិករ ក្រុមហ៊ុន ការដ្ឋាន កសិដ្ឋាន សិប្បកម្មដ្ឋាន និង អតិថិជនដែលមានតម្រូវការប្រើប្រាស់គ្រឿងផ្ទុះត្រូវសុំអាជ្ញាប័ណ្ណពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ជំពូកទី ៤
ទោសប្បញ្ញត្តិ

មាត្រា ១៥.-

ជនណា ដែលប្រព្រឹត្តផ្ទុយពីខ្លឹមសារ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ជំពូកទី ៥
អន្តរប្បញ្ញត្តិ

មាត្រា ១៦.-

ក្នុងរយៈពេល ៣ (បី) ខែ យ៉ាងយូរ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ជនណាដែលបាន កាន់កាប់ កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវយកមកចុះបញ្ជីនៅក្រសួងមហាផ្ទៃជាកំហិត ។

ជំពូកទី ៦
អវសានប្បញ្ញត្តិ

មាត្រា ១៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៤ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សម្រេច

មាត្រា ១.- តែងតាំងលោក **ឡោ សារឿន** បច្ចុប្បន្នអគ្គនាយករងទូរគមនាគមន៍កម្ពុជា ជាអគ្គនាយកក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា ជំនួសលោក **ញឹក គោសល្យវិជ្ជា** ដែលត្រូវផ្លាស់ទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ វិញ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមានចែងក្នុងមាត្រា ២
- ឯកសារ កាលប្បវត្តិ.

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៤៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សម្រេច

មាត្រា ១.-

តែងតាំងក្រុមប្រឹក្សាភិបាលទូរគមនាគមន៍កម្ពុជា សំរាប់អាណត្តិទី ២ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **កុយ ពុំ** តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធាន

២- ឯកឧត្តម	**ហង់ជួន ណារ៉ុន**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៣- ឯកឧត្តម	**គីម រ័ត្នទិសិដ្ឋ**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤- លោក	**ហារក់ រ័ត្ន**	តំណាងក្រសួងមហាផ្ទៃ	សមាជិក
៥- លោក	**ឡៅ សារឿន**	អគ្គនាយកទូរគមនាគមន៍កម្ពុជា	សមាជិក
៦- **តំណាងនិយោជិត**		ទូរគមនាគមន៍កម្ពុជា	សមាជិក
៧- ឯកឧត្តម	**ខួន ម៉េងគិច**	តំណាងសភាពាណិជ្ជកម្ម	សមាជិក

មាត្រា ២.-

សមាសភាពក្រុមប្រឹក្សាភិបាល ដូចមានចែងក្នុងមាត្រា ១ ត្រូវបានតែងតាំងសំរាប់របស់ពេល ៣ (បី) ឆ្នាំ ។ អាណត្តិនេះ អាចបន្តជាថ្មីទៀតបាន ។

មាត្រា ៣.-

មុខងាររបស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ចប់បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ដែលបានពិភាក្សាសម្រេចលើគណនី នៃការិយបរិច្ឆេទទី ៣ របស់ទូរគមនាគមន៍កម្ពុជា ។ សមាជិកក្រុមប្រឹក្សាភិបាលអាចត្រូវផ្លាស់ប្តូរដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាមុី ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ប្រធានសភាពាណិជ្ជកម្ម និងសាមុីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ដូចមានចែងក្នុងមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ.*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៣៦៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រី ហេង សំរិន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនក្រុមការងារមូលដ្ឋាន ចំនួន ០៥រូប ដែលបានចូលរួមចំណែកស្តារនិងអភិវឌ្ឍន៍មូលដ្ឋាន នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១-លោកជំទាវ **ស៊ឿន សុខហេង**

២-លោកជំទាវ **ឃួន សោភា**

៣-លោកជំទាវ **ម៉ឹន កនិកា**

៤-លោកជំទាវ **អ៊ីម ហ្គិចគីម**

៥-លោកជំទាវ **កែប សម្បត្តិ**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រីហេងសំរិន និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា   ជាតិ   សាសនា   ព្រះមហាក្សត្រ

លេខ: ៣៩៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតាំងស៊ប់ក្នុង **ឋានន្តរស័ក្តិ ក្រមការ** នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ដោយគិតចាប់ពី **ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧** នូវមន្ត្រីរាជការស៊ីវិល ចំនួន ០៩ រូប មានរាយនាមដូចខាងក្រោម :

១ - កញ្ញា **ឌុយ សុគន្ធភក្រ្តា** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
២ - លោក **លឹម តុងហួត** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
៣ - លោក **សុខ សំណាង** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
៤ - លោក **ឌុច សុភ័ណ្ឌ** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
៥ - លោក **ហ៊ុម លីម៉េង** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
៦ - លោក **អៀង ពិសិដ្ឋ** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
៧ - លោក **ឡុង គីស៊ីង** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
៨ - លោក **នៅ ទ័ត** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១
៩ - លោក **អ៊ី ធារិន** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១១

មាត្រា ២ : ត្រូវបានតាំងស៊ប់ក្នុង **ឋានន្តរស័ក្តិ ក្រមការ** នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ដោយគិតចាប់ពី **ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៧** នូវមន្ត្រីរាជការស៊ីវិល ចំនួន ៧៦ រូប មានរាយនាមដូចខាងក្រោម :

១ - លោក **ហោ ស៊ីដែត** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១៤
២ - លោកស្រី **សាមុត សុតី** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១៤
៣ - កញ្ញា **ហួយ ចន្ទរមនា** ឋានន្តរស័ក្តិ ក្រមការ ថ្នាក់លេខ ១៤

៤ -	លោក អ៊ុន សុវណ្ណា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៥ -	លោក តុច រតនា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៦ -	លោក ទាំត វៀមម៉ា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៧ -	កញ្ញា រស់ ចិន្តា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៨ -	លោក ពិ ធីរ៉ា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៩ -	លោក ជា វិចិត្រតនៈ	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១០ -	លោក សឹក ប៊ូរ៉ា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១១ -	លោក ឈឿន ប៊ុណ្ណារ័ត្ន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១២ -	លោក ថុន គីរម្យ	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១៣ -	លោក នួន មាសចំរើន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១៤ -	លោក ម៉ុន ម៉ានិត	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១៥ -	លោក ម៉ូ វណ្ណនា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១៦ -	លោកស្រី ម៉ប់ ម៉ាណេត	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១៧ -	លោក ម៉េ វណ្ណារី	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១៨ -	កញ្ញា យូន សុម៉ាលីន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
១៩ -	លោក សាន សំរួល	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២០ -	កញ្ញា យស់ ហ្វីណុន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២១ -	លោក ម៉ែត ឡុង	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២២ -	លោក ជា សុរក្សា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២៣ -	លោក សុន្ធ សារឿន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២៤ -	លោក ជុំ លីវណ្ណារ័ត្ន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២៥ -	លោក ជាតិ សុផល	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២៦ -	លោក យង់ សុគា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២៧ -	លោក អាន សុផល	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២៨ -	លោក ម៉ុត រ៉ាយ	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
២៩ -	កញ្ញា សុន្ធ សោភ័ណ	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣០ -	លោក ម៉ែន សាម៉ុល	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣១ -	លោក អ៊ុក សុក្កា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣២ -	លោក នុត លីដា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣៣ -	លោក អ៊ុន ប៊ុនថន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣៤ -	លោក ចាន់ ចន្ទចំណាន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣៥ -	លោក យស រចនា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣៦ -	កញ្ញា សុត គីរីភញ្ញនា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣៧ -	លោក ស្រី ហេង	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣៨ -	លោក សុខ សៀងហុង	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៣៩ -	លោក ជួន សំណាង	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤០ -	លោកស្រី គង សុធីតា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤១ -	កញ្ញា ជឿង វណ្ណា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤២ -	លោក អ៊ុត សោភ័ណ្ណ	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤៣ -	លោក យុង វាសនា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤៤ -	លោក មាស យុត្តិណារ៉ាន់	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤៥ -	លោក ទាន់ សុខុម	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤៦ -	លោក ម៉ៃ មីនា	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤៧ -	លោក សម សំអុន	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤
៤៨ -	លោក ឆៅ វណ្ណៈ	ឋានន្តរស័ក្តិ ក្រមការ	ថ្នាក់លេខ ១៤

៤៩ - លោក ហ៊ាង សុផារី បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥០ - លោក រិត សុវណ្ណ បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥១ - លោក ឃ្លោក សារ៉េត បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥២ - លោក សុត្រ សាន បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥៣ - លោក ញ៉ៀម ចាំ៉ង បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥៤ - លោក ឈាន ច័ន្ទរិទ្ធី បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥៥ - កញ្ញា ម៉ា សារឌី បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥៦ - លោក ហោ ម៉ុនហួរ បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥៧ - លោក សក់ សំរិទ្ធិក្បៀ បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥៨ - លោក ខួន ច័ន្ទរុទ្ធី បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៥៩ - លោក ហេល ឆេងហុង បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦០ - កញ្ញា ស៊ីម ស៊ីដារ៉ត្ន បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦១ - លោក លឹម ពិសិដ្ឋ បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦២ - លោក ហ៊ិន យ៉ារិទ្ធ បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦៣ - លោកស្រី នួន ពុទ្ធារី បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦៤ - លោក ស៊ុន ចំណាន បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦៥ - លោក ស៊ូ មុនីសិរី បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦៦ - លោក សុខ ប៊ូរ៉ា បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦៧ - លោក សែស សារឿន បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦៨ - លោក ជា ពិសិដ្ឋ បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៦៩ - លោក លឹម តយ បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៧០ - លោក សុខ ចិន្តា បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៧១ - លោក រិន ធារ៉ា បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៧២ - លោក ខាំ ចាន់តូរ៉ា បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៧៣ - លោក ឯម ច័ន្ទទាសនា បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៧៤ - លោក ញ៉ែម ធុល បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៧៥ - លោក គ្រាំ មេត្តា បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤
៧៦ - លោក សេង អេន បំពេញការងារ ក្រមការ ថ្នាក់លេខ ១៤

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
 (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៧១ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដាឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា ១: ត្រូវបានតែងតាំងលោកវរសេនីយ៍ឯក **ឡេស់ សុផាត** អត្តលេខ ០០១៣៨៨ ជាជំនួយការឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិមានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខា ធិការដ្ឋាន មុខងារសារធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមាន ចែងក្នុង មាត្រា១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ [illegible] ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

ដូចមាត្រា ២

ឯកសារ កាលប្បវត្តិ

PSSD 2008

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតអគ្គិសនី កម្ពុជា ជាមួយក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ២៨៤ អនក្រ.តត ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងលោក **កែវ រតនៈ** ជាអគ្គនាយកអគ្គិសនីកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស ម្រេ ច

មាត្រា ១.-

ត្រូវបានតែងតាំងឯកឧត្តម **ទុន លាន** បច្ចុប្បន្នអគ្គនាយក នៃអគ្គនាយកដ្ឋានថាមពល នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជាប្រធានក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់រយៈពេលនៅសល់ នៃអាណត្តិទី ៤ ។

មាត្រា ២.-

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦២៩ ពណ.នគក

ភ្នំពេញថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **(ខេមបូឌា) មីលីហ្គេន ខនត្រេកធីង អ៊ីន**
(CAMBODIA) MILLIGAN CONTRACTING INC.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 3601/07E** ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ម៉ែន សុភ័ក្ត្រ** ប្រធានក្រុមប្រឹក្សាភិបាល
លោក **TERRY GEORGE MILLIGAN** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៨៥៣ មហាវិថីព្រះមុនីវង្ស (៩៣) សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្ដូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សព្វផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាឃ្លាំង និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

អ៊ឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៣០ ពណ.នតក

ភ្នំពេញថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេ.អិន.ឌី. ឌីវេឡុបមេន**
K. N. D. DEVELOPMENT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9936/07P** ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

លោក	**គីម សុគុណា**	ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី	**ស៊ុន សុម៉ាលីដារ៉ានី**	អភិបាល
លោកស្រី	**នៃ ចាន់ឌី**	អភិបាល
លោក	**ជា បូនី**	អភិបាល
កញ្ញា	**ជា ស៊ីនដា**	អភិបាល
លោកស្រី	**ស សុគា**	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣C ផ្លូវលេខ ៤១៨ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកុំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកវិនិយោគ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៣១ ពណ.នគក

ភ្នំពេញថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៊ីវ៉ាកូ បាយអូ លេប័រទ័រី (ខេមបូឌា) ខូ អិលធីឌី**

BIWAKO BIO LABORATORY (CAMBODIA) Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 3596/07E** ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **LIM KWANG NAM** ប្រធានក្រុមប្រឹក្សាភិបាល

លោក **NIINA KENTARO** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៥០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៧៧ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-វិនិយោគលើវិស័យឧស្សាហកម្មជីវថាមពល
-វិនិយោគលើវិស័យថាមពល ដែលអាចបង្កើតឡើងវិញលើវិស័យអគ្គិសនី
-វិនិយោគលើវិស័យកសិកម្ម ដាំ ព្រៃឈើ នេសាទ និង ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យកសិ-ឧស្សាហកម្ម និងជីសម្បទាន
-សហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ
- នីហរ័ណ អាហរ័ណ ទំនិញ សំភារៈបរិក្ខារគ្រប់ប្រភេទ
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សិក្សាស្រាវជ្រាវ គ្រប់គ្រង និងអភិវឌ្ឍន៍ ទីផ្សារពាណិជ្ជកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ស៊ិន

ចាម ប្រសិទ្ធ

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៣៧ ពណន.នគក

ភ្នំពេញថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **តារា រីវើរ បូត**

TARA RIVERBOAT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 3602/07E** ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **PLANK PETER FRANCIS** ប្រធានក្រុមប្រឹក្សាភិបាល

លោក **GARDINER PETER JOHN** អភិបាល

លោក **HUTCHINS BENJAMIN JOH** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៣០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិចុងឃ្នៀស ឃុំចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប ។

៥- កម្មវត្ថុអាជីវកម្ម : -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -ដឹកជញ្ជូនភ្ញៀវទេសចរណ៍

-ដឹកជញ្ជូនអ្នកដំណើរ -សេវាបញ្ជូននិងចែកចាយទំនិញ

-ទេសចរណ៍ : ទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន ម៉ាស្សា រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើវិធីគ្រប់គ្រងពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

ហ៊ឹម-ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តសៀមរាប
- មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៦៣៤ ពណ.នតក

ភ្នំពេញថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សាណាន អេគ្រីខលឈ័រ ឌីវេឡុបមេន អេន ឡូជីស្ទីក**
SANAN AGRICULTURES DEVELOPMENT AND LOGISTICS Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9935/07P ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ស្ពាត សាណាន** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **ហ៊ីម មឿន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥០៨ ផ្លូវលំ ១៣ B2 សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើនៅក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន ទំនិញ ចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

- សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៣៥ ពណ.នគក

ភ្នំពេញថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៊ុក វីត ណូ បឌើរ**

BOOKS WITH NO BORDERS Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 3615/07E** ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **MATTHEW RAYMOND WHITTAKER**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៦៥ ផ្លូវបូរីកម្មករ សង្កាត់មិត្តភាព ក្រុងព្រះសីហនុ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាយកពន្ធនិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត ...

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប៉ាំ_ស៊ីផន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងព្រះសីហនុ
- មន្ទីរពាណិជ្ជកម្មក្រុងព្រះសីហនុ "មុខការ"
- ឯកសារ -កាលប្បវត្តិ